**សាលាអន្តរជាតិ ណតប្រ៊ីង(NISC)**

## គោលការណ៍ការការពារ និងសុវត្ថិភាពរបស់កុមារ

### ការប្តេជ្ញារបស់យើងចំពោះសុវត្ថិភាពកូនរបស់លោកអ្នក

នៅសាលារៀនអន្តរជាតិណតប្រ៊ីង យើងផ្តល់អាទិភាពដល់សុវត្ថិភាព និងសុខុមាលភាពកូនៗរបស់លោកអ្នកជាចម្បង។ យើងជឿថាសិស្សានុសិស្សទាំងអស់អាចរីកចម្រើនទៅបានល្អបំផុតនៅពេលដែលពួកគេស្ថិតនៅក្នុងបរិយាកាសមួយដែលមានសុវត្ថិភាព។ គោលបំណងរបស់យើងគឺចង់បណ្តុះចំណេះដឹង និងសមត្ថភាពដល់កូនៗរបស់លោកអ្នកដែលអាចឲ្យពួកគេបានយល់ច្បាស់ និងចេះជ្រើសរើសអ្វីដែលមានសុវត្ថិភាពបំផុតសម្រាប់ខ្លួនគេ តាមរយៈមេរៀនអប់រំអំពីខ្លួនឯង សុខភាព និងសង្គម។

### គោលការណ៍សំខាន់ៗ

1. **សុខុមាលភាពកុមារជាអទិភាពទីមួយ**៖ កុមារទាំងអស់មានសិទ្ធិទទួលបានការការពារពីគ្រោះថ្នាក់ ដោយមិនគិតពីជីវប្រវត្តិឡើយ។
2. **បង្កើតបរិយាកាសដែលមានសុវត្ថិភាព**៖ យើងធានានឹងប្រាកដថាសិស្សានុសិស្សទាំងអស់ទទួលបានអារម្មណ៍សុវត្ថិភាពនៅក្នុងសាលារៀន។
3. **ការអប់រំសម្រាប់សុវត្ថិភាព**៖ យើងផ្តល់កម្មវិធីសិក្សាដ៏ពេញលេញដើម្បីជួយដល់សិស្សានុសិស្សឲ្យចេះនិងយល់ពីរបៀបរក្សាសុវត្ថិភាពផ្ទាល់ខ្លួន។
4. **ការសហការជាមួយឪពុកម្តាយ**៖ យើងធ្វើការយ៉ាងជិតស្និទ្ធជាមួយឪពុកម្តាយ និងអ្នកជំនាញផ្សេងៗទៀតដើម្បីធានាការការពារនិងសុវត្ថិភាពកូនៗរបស់លោកអ្នក។
5. **ការគាំទ្រសម្រាប់តម្រូវការទាំងអស់**៖ យើងទទួលស្គាល់ថាសិស្សានុសិស្សមួយចំនួនអាចត្រូវការការគាំទ្របន្ថែមដោយសារមូលហេតុផ្សេងៗ។

**គោលបំណងរបស់យើង**

- **បរិយាកាសសិក្សាដែលមានសុវត្ថិភាព**៖ យើងនឹងខិតខំបង្កើតបរិយាកាសដែលមានសុវត្ថិភាពសម្រាប់កូនៗរបស់លោកអ្នក។
- **ការយល់ដឹងរបស់បុគ្គលិក**៖ យើងមានវគ្គបណ្តុះបណ្តាលនិងបង្រៀនបុគ្គលិកឱ្យយល់ដឹងអំពីការការពារសុវត្ថិភាពរបស់កុមារ និងកាតព្វកិច្ចរបស់ពួកគេ។
- **ការប្រាស្រ័យទាក់ទងដែលច្បាស់លាស់**៖ យើងរក្សាប្រព័ន្ធទំនាក់ទំនងដែលច្បាស់លាស់អំពីការការពារនិងសុវត្ថិភាពកុមារ។
- **នីតិវិធីក្នុងការរាយការណ៍**៖ យើងមាននីតិវិធីច្បាស់លាស់សម្រាប់រាយការណ៍នៅពេលមានបញ្ហាផ្សេងៗ។

**តើអ្នកណាជាអ្នកទទួលបន្ទុកផ្នែកការការពារនិងសុវត្ថិភាពរបស់កុមារ?**

- **នាយកសាលា**៖ នាយកសាលា Frances Morton មានភារកិច្ចក្នុងការទទួលខុសត្រូវយ៉ាងខ្ពស់បំផុតក្នុងការការពារនិងសុវត្ថិភាពនៅសាលាអន្តរជាតិណតប្រ៊ីដ។
- **អ្នកដឹកនាំផ្នែកសុវត្ថិភាពកុមារ(DSLs)**៖ នៅសាលាណតប្រ៊ីដយើងមានអ្នកដឹកនាំផ្នែកសុវត្ថិភាពកុមាររួមមាន(DSLs)៖

  - Sarah Newton: sarah.newton@nisc.edu.kh
  - Aidan Stallwood: aidan.stallwood@nisc.edu.kh
  - Robbie Alexander: robert.a@nisc.edu.kh
  - Karel Van der Linden: karel.vanderlinden@nisc.edu.kh

**តើអ្នកត្រូវធ្វើដូចម្តេចប្រសិនបើអ្នកមានការព្រួយបារម្ភឬជួបបញ្ហាក្នុងករណីណាមួយ?**

ប្រសិនបើលោកអ្នកសង្ស័យថាកូនរបស់លោកអ្នកប្រឈមនិងហានិភ័យ យើងសូមលើកទឹកចិត្តឱ្យពួកគេនិយាយជាមួយមនុស្សដែលពួកគេជឿទុកចិត្តបំផុតនៅសាលា។ បុគ្គលិកទាំងអស់ត្រូវបានបណ្តុះបណ្តាលឱ្យស្តាប់ ផ្តល់ការលួងលោម និងកត់ត្រាទុកដោយប្រុងប្រយ័ត្ន។

**របៀបដោះស្រាយនៅពេលដែលកូនៗរបស់លោកអ្នកជួបបញ្ហា៖**

1. **ស្តាប់**៖ យើងចំណាយពេលស្តាប់យ៉ាងយកចិត្តទុកដាក់ចំពោះការព្រួយបារម្ភរបស់កូនលោកអ្នក។

2. **ផ្តល់ការលួងលោម**៖ យើងផ្តល់ការលួងលោមដោយមិនសន្យានូវអ្វីដែលយើងមិនអាចធ្វើបាន។

3. **សួរសំណួរបើកចំហ**៖ យើងសួរដើម្បីស្វែងយល់បន្ថែមដោយមិនបង្ខំ។

4. **កត់ត្រា**៖ យើងកត់ត្រាទុករាល់ការសន្ទនាយ៉ាងត្រឹមត្រូវ។

5. **រាយការណ៍**៖ យើងបញ្ជូនព័ត៌មានទៅកាន់អ្នកទទួលបន្ទុកផ្នែកសុវត្ថិភាពកុមារ (DSL) ដើម្បីធ្វើការបន្ត។

**ការបណ្តុះបណ្តាលបុគ្គលិក**

បុគ្គលិកទាំងអស់ទទួលបានការបណ្តុះបណ្តាលការការពារកុមារនៅពេលចូលធ្វើការនិងរៀងរាល់ពីរឆ្នាំម្តង។ អ្នកទទួលបន្ទុកផ្នែកសុវត្ថិភាពកុមារ (DSLs) ទទួលបានការបណ្តុះបណ្តាលមួយក្នុងកម្រិតខ្ពស់ទៅតាមស្តង់ដារថ្មីៗ។

**ចំណុចសំខាន់ដែលត្រូវផ្តោតបន្ថែម**

- **ការជ្រើសរើសបុគ្គលិកដោយប្រុងប្រយ័ត្ន**៖ យើងបានត្រួតពិនិត្យមើលជីវប្រវត្តិបុគ្គលិក និងអ្នកស្ម័គ្រចិត្តទាំងអស់។
- **ការគាំទ្រផ្នែកសុខភាពផ្លូវចិត្ត**៖ យើងផ្តល់អាទិភាពនិងផ្តល់ជំនួយដល់សិស្សដែលមានបញ្ហាផ្លូវចិត្ត។

**ការដោះស្រាយបញ្ហារើសអើង ឬការបំពានរវាងមិត្តភក្តិក្នុងសាលា**

យើងយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះការរើសអើង នឹងធ្វើការស៊ើបអង្កេតរាល់របាយការណ៍ដែលបានរាយការណ៍។ ហើយយើងក៏មាននីតិវិធីច្បាស់លាស់ក្នុងការដោះស្រាយបញ្ហានីមួយៗនិងជួយគាំទ្រដល់សិស្សទាំងអស់ដែលពាក់ព័ន្ធ។

**សរុប**

គោលការណ៍ការការពារនិងសុវត្ថិភាពកុមាររបស់យើងត្រូវបានរៀបចំឡើងដើម្បីធានាសុវត្ថិភាពដល់កូនរបស់លោកអ្នក។ យើងសូមលើកទឹកចិត្តឱ្យលោកអ្នកសហការជាមួយសាលា និងជួយរំលឹកកូនៗឱ្យក្លាហានក្នុងរាយការណ៍ពីបញ្ហាទៅដល់មនុស្សធំដែលពួកគេអាចទុកចិត្តបាន។ នេះគ្រាន់តែជាសង្ខេបតែប៉ុណ្ណោះ ប្រសិនបើលោកអ្នកចង់បានគោលការណ៍ពេញ សូមទាក់ទង Robbie Alexander តាមអ៊ីម៉ែល robert.a@nisc.edu.kh។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងទៅកាន់អ្នកទទួលបន្ទុកផ្នែកសុវត្ថិភាពកុមារ(DSLs) នៅសាលាអន្តរជាតិណតប្រ៊ីដ ។ សុវត្ថិភាពកូនរបស់លោកអ្នកគឺជាអាទិភាពចម្បងបំផុតសម្រាប់យើង។